បង្កើនសក្តានុពលខ្លួនឯង

សមាគមអ្នកនិពន្ធខ្មែរ

# រៀនឱ្យចេះ
# ប្រើចំណេះឱ្យមានប្រយោជន៍

## ប្រសិទ្ធភាពនៃការរៀន
## ប្រសិទ្ធភាពនៃការហ្វឹកហាត់ខួរក្បាល

www.elibraryofcambodia.org

គីម ចាន់ណា
រៀបរៀង

www.facebook.com/7khmer
Fb : Entertainment And Knowledge

# រៀនឱ្យចេះ

## ប្រើចំណេះឱ្យមានប្រយោជន៍

ប្រសិទ្ធភាពនៃការរៀន

ប្រសិទ្ធភាពនៃការហ្វឹកហាត់ខួរក្បាល

គីម ចាន់ណា

រៀបរៀង

www.elibraryofcambodia.org

www.facebook.com/7khmer
Fb : Entertainment  And Knowledge

“ បើអ្នកគិតថា ការសិក្សាត្រូវចំណាយខ្ពស់ពេក
ចូរអ្នកសាកល្បងចាយទៅលើភាពល្ងង់ខ្លៅសាក-លមើល? ”

If you think education is expensive,
try ignorance.

**ឌិក បក – Derek Bok**

នាយកមហាវិទ្យាល័យ ហាវើដ

**១៩៧១-៩១**

www.elibraryofcambodia.org

www.facebook.com/7khmer
Fb : Entertainment And Knowledge

# អារម្ភកថា

ជីវិតមនុស្សម្នាក់ៗតែងទទួលស្គាល់ និងគោរពឱនលំទោនចំពោះពាក្យថា "រៀន" គ្រប់ៗគ្នា តែពាក្យ "រៀន" ពុំមែនចេះតែទទួលស្គាល់មនុស្សយើងតបមកយើងវិញដោយងាយៗនោះឡើយ។ អ្នកខ្លះខំសំពះតាំងពីក្តារច្នួនបួងសួងសុំឱ្យរៀនចេះ ប្រឡងជាប់ ឱ្យចាំនេះ ចាំនោះកុំឱ្យភ្លេច កុំឱ្យខុស ឬបើខុសអ្វីម្តងហើយកុំឱ្យខុសម្តងទៀត។ តែអ្នកមួយចំនួនអាចធ្វើបាន ឯអ្នកមួយចំនួនទៀតនៅតែមិនអាចធ្វើបានទៅតាមចិត្តរបស់ខ្លួនឡើយ។ តើមកពីហេតុអ្វី?

ថ្វីត្បិតតែក្នុងជីវិតយើងម្នាក់ៗកើតមក ជួបប្រទះនឹងការរៀនដូចៗគ្នា តែវិធីទទួលយកការរៀនរបស់មនុស្សម្នាក់ៗ មានលក្ខណៈផ្សេងៗគ្នា ដែលជាហេតុធ្វើឱ្យការរៀនក្នុងជីវិតមនុស្សម្នាក់ៗ ក៏ទទួលផលខុសគ្នាអញ្ចឹងដែរ។

សៀវភៅ "**រៀនឱ្យចេះ ប្រើចំណេះឱ្យមានប្រយោជន៍**" បានប្រមូលផ្តុំគន្លឹះ បទពិសោធន៍ ឧទាហរណ៍ ព្រមទាំងលទ្ធផលនៃការស្រាវជ្រាវមួយចំនួនយកមកបង្ហាញជូនដល់អស់លោកអ្នកអាន ព្រមទាំងប្អូនៗសិស្ស និស្សិត ក្នុងការស្វែងយល់ទៅលើផលប្រយោជន៍នៃការរៀន ផលអាក្រក់នៃការមិនរៀន ព្រមទាំងវិធានការណ៍មួយចំនួនដើម្បីបង្កើនប្រសិទ្ធភាពនៃការរៀនផងដែរ។

នៅវគ្គខាងក្រោយនៃសៀវភៅ ក៏មានបង្ហាញជូនអំពីប្រសិទ្ធភាពនៃការប្រើខួរក្បាល វិធីអានឱ្យបានលឿន វិធីចងចាំ និង វិធីស្តាប់ ដែលយើងខ្ញុំគិតថាវាពិតជាមានប្រយោជន៍ដល់អ្នកអានជាក់ជាមិនខាន។

www.elibraryofcambodia.org

www.facebook.com/7khmer
Fb : Entertainment And Knowledge

ការត្រៀមខ្លួនឲ្យទៅជាអ្នករៀនសូត្រពេញមួយជីវិតរបស់មនុស្សម្នាក់ៗ គឺជាអ្វីដែលប៉ះពាល់ទៅដល់ចាកជីវិតរបស់គេរៀងៗខ្លួន ព្រមទាំងជាបច្ច័យដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍប្រទេសជាតិផងដែរ។

ការដែលបង្រៀនមនុស្សឲ្យរៀនទៅតាមធម្មតា ចេះតែរៀនៗទៅ វានឹងពុំសូវបានលទ្ធផលជាដុំកំភួនអ្វីប៉ុន្មានឡើយ។ យើងត្រូវតែមានវិធីជំរុញទឹកចិត្តឲ្យមនុស្សរៀនដើម្បីយកទៅបង្កើនការផលិត ច្នៃប្រឌិតឲ្យកើតអ្វីល្អៗ ដែលមានប្រយោជន៍ដល់ប្រទេសជាតិ នោះទើបជាការល្អ។

ការរៀនគួរតែធ្វើឲ្យបានជាបន្ត កុំឲ្យគាំងនៅមួយកន្លែង ហើយគួរតែផ្ទេរបន្តនូវអ្វីល្អៗសម្រាប់អនុជនជំនាន់ក្រោយ និងអ្វីដែលសំខាន់ គឺការរៀនវិជ្ជាផ្សេងៗ ត្រូវគួបផ្សំផ្នែកគុណធម៌ផងដែរ ដែលយើងតែងនិយាយថា សាងទាំងមនុស្សពូកែ និងមនុស្សល្អព្រមជាមួយគ្នានោះឯង។

យើងខ្ញុំសូមអរគុណដល់អស់លោកអ្នកអាន ព្រមទាំងសិស្ស និស្សិត ដែលបានជួយគាំទ្រឲ្យយើងខ្ញុំចេះតែមានកម្លាំងបន្តផលិតសៀវភៅតទៅមុខ ដោយខំសម្រិតសម្រាំងទាំងគុណភាព ទាំងខ្លឹមសារ ដើម្បីឲ្យអស់លោកអ្នក និងប្អូនៗ បានទទួលប្រយោជន៍ខ្ពស់បំផុតពីសៀវភៅនីមួយៗរបស់យើង។

ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩

គីម ចាន់ណា

www.elibraryofcambodia.org

www.facebook.com/7khmer
Fb : Entertainment  And Knowledge

| មាតិកា | ទំព័រ |
|---|---|
| ១- ដំណើរឆ្ពោះទៅរកជោគជ័យ | ៩ |
| ២- ដំណើរការនៃ "ការរៀន" | ២៥ |
| ៣- សារប្រយោជន៍នៃ "ការរៀន" | ៤៣ |
| ៤- ប្រភេទនៃ "ការរៀន" | ៥៥ |
| ៥- ផលល្អនៃ "ការរៀន" | ៦៥ |
| ៦- អ្វីគួររៀន? អ្វីមិនគួររៀន? | ៨១ |
| ៧- ឥរិយាបថជំរុញដល់ "ការរៀន" | ៩៧ |
| ៨- ឥរិយាបថជាឧបសគ្គដល់ "ការរៀន" | ១០៩ |
| ៩- ប្រភពនៃ "ការរៀន" | ១២៣ |
| ១០- ចង្កូលដៃនិងដួងច័ន្ទ | ១៣៥ |
| ១១- យល់ដឹងអំពីខួរក្បាល | ១៤១ |
| ១២- តិចនិចហ្វឹកហាត់ខួរក្បាលសម្រាប់ប្រើក្នុងពេលរៀន | ១៥៩ |
| ១៣- បណ្តាំផ្ញើ សម្រាប់អ្នកចង់រៀនពូកែ | ១៨៣ |

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

ការចង់ចេះចង់ដឹង គឺជាទ្រព្យដ៏មានតម្លៃ
គឺជាការជក់ចិត្តជក់អារម្មណ៍នឹងការរៀនសូត្រ។
បើអ្នកបំផ្លាញវាចោល
អ្នកនឹងធ្វើឱ្យជីវិតរបស់ខ្លួនទៅជាគ្មានរសជាតិ និងគួរឱ្យធុញទ្រាន់។

**ចន រ៉ាស់ស្គិន**

Curiosity is a gift, a capacity of pleasure in knowing,
which if you distroy,
you make yourselves cold and dull.

John Ruskin (1819 -1900)
English author and art critic

www.facebook.
Fb : Entertainm

បើចង់ឈ្នះគូប្រកួត

អ្នកត្រូវសិក្សាក្បាច់សំខាន់ៗរបស់គូប្រកួតឱ្យអស់ជាមុនសិន។



www.elibraryofcambodia.org
www.facebook.
Fb : Entertainm

# ១

# ដំណើរឆ្ពោះទៅរកជោគជ័យ

## ✿ "រៀនយល់ដឹង" ជាដំណើរការរបស់មនុស្សជាតិ

ជីវិតរបស់មនុស្សយើង កកើតឡើងជាមួយនឹងពាក្យ "រៀន" ចាប់តាំងតែពីការរៀនដោយសភាវគតិក្នុងការសម្របសម្រួលខ្លួន ពេលចេញពីពោះម្ដាយ រហូតដល់ពេលបើកភ្នែកមើលឃើញលោកយើង ហើយបន្ទាប់ពីនោះមក មនុស្ស ត្រូវអាស្រ័យនៅជាមួយពាក្យ "រៀន" អស់ពេញមួយជីវិតរបស់ខ្លួន។

ក្មេងរៀនយល់ដឹងថា ភ្លើងវាធ្វើឲ្យក្ដៅនិងមានគ្រោះថ្នាក់ នៅពេលដែលគេលួចគូសឈើគូសលើកដំបូង ហើយត្រូវភ្លើងរលាកដៃ។

កូនៗរៀនយល់ដឹងថា ពេលណាគេប្រព្រឹត្តអំពើល្អ គេនឹងបានទទួលរង្វាន់ពីឪពុកម្ដាយ។

ក្មេងជំទង់ៗបានរៀនដឹងថា ប្រសិនបើគេកែខ្លួនឲ្យទាន់សម័យ គេនឹងបានមិត្តភក្តិនិយមចូលចិត្ត។

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

អ្នកម្ដាយបានយល់ដឹងថា ការប្រាស្រ័យទាក់ទងជាមួយកូនឲ្យបានជាប់ជាប្រចាំ នឹងធ្វើឲ្យមានការយល់ចិត្តគ្នាកាន់តែច្រើន ព្រមទាំងជាការជួយបង្ហាញផ្លូវដល់កូនបានសមរម្យផងដែរ។

នារីក្មេងៗរៀនយល់ថា បើចង់រក្សាសុវត្ថិភាពរបស់ខ្លួនក្នុងសង្គម គេមិនត្រូវដើរលេងពេលយប់ជ្រៅ មិនដើរនៅតាមទីស្ងាត់ ឬមិនគួរស្លៀកសំពត់ណាដែលខ្លីចពេកនោះទេ។

សិស្ស និស្សិត រៀនយល់ដឹងថា ប្រសិនបើខ្លួនមិនបានហ្វឹកហាត់រៀនភាសាអង់គ្លេសឲ្យបានស្ទាត់ជំនាញទេ តទៅអនាគត គេមុខជាពិបាករកការងារធ្វើជាមិនខាន។

អ្នកជំនួញរៀនស្វែងយល់ថា ប្រ.សិនបើមិនព្រមកែលម្អទៅលើបែបបទគ្រប់គ្រងរបស់ក្រុមហ៊ុនទេ ក្រុមហ៊ុនរបស់ខ្លួននឹងមិនអាចរីកចម្រើនធំធាត់តទៅទៀតបានឡើយ ក្នុងពេល ១០ឆ្នាំ ខាងមុខ។

អ្នកដឹកនាំប្រទេសស្វែងយល់ថា ប្រសិនបើមិនបានរៀបចំទិសដៅអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ ឲ្យសមស្របទៅតាមរបត់ដ៏គ្មានព្រំដែនរបស់ពិភពលោកទេនោះ ប្រទេសជាតិនឹងត្រូវដើរយឺតជាងប្រទេសដទៃអស់កាលជាច្រើនតំណទៅទៀត។

យើងគ្រប់គ្នា តែងរៀនសូត្រស្វែងយល់ចាប់ពីរឿងកំប៉ិកកំប៉ុករហូតដល់រឿងធំដុំ ដោយឆ្លងកាត់តាមដំណើរការផ្សេងៗក្នុងជីវិតដូចជា រៀនធ្វើយកបទៅនឹងអ្វីផ្សេងៗតាមគំរូដែលឪពុកម្ដាយធ្លាប់ធ្វើ រៀនស្វែងយល់អំពីការរស់នៅដោយសារបទពិសោធន៍ផ្សេងៗក្នុងជីវិត រៀន[illegible] បំណេះដឹងទាំងឡាយតាមរយៈគ្រូបង្រៀននិងក្បួនតម្រា រៀនពីការចងសម្ព័ន្ធ

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

ឬការភ្ជាប់ទំនាក់ទំនងតាមរយៈសកម្មភាពរបស់មនុស្សក្នុងសង្គម រៀនយល់ដឹងខុសដឹងត្រូវ តាមរយៈបែបបទខាងសីលធម៌និងក្រិត្យក្រមនៃច្បាប់ រៀនស្វែងយល់អំពីការបត់បែន និងការត្រៀមខ្លួនតាមរយៈទិន្នន័យរបស់បណ្ដាញព័ត៌មានផ្សេងៗ ហើយជាញឹកញាប់ផងដែរ យើងបានរៀនសូត្រតាមរយៈកំហុសឆ្គង ការខកបំណង បរាជ័យ...ពីស្ថានការណ៍ដែលកើតឡើងដោយគ្មានការព្រាងទុកក្នុងជាកជីវិតរបស់ខ្លួន។

យើងអាចនិយាយថា

**"ការរៀនយល់ដឹង" ជាការពង្រឹងស្ថិរភាពដល់ជីវិតរបស់យើង។**

ព្រោះការរៀនយល់ដឹង ជួយឱ្យយើងរៀបចំខ្លួនបានសមស្របទៅតាមស្ថានការណ៍ដែលត្រូវបត់បែន។ ការរៀនយល់ដឹង ជួយឱ្យយើងអាចចម្រាញ់យកប្រយោជន៍អំពីហេតុការណ៍ដែលកើតឡើង។ ការរៀនសូត្រ នាំឱ្យដុះដាលនូវសតិបញ្ញា ដែលអាចឱ្យយើងសម្រេចចិត្តលើរឿងរ៉ាវទាំងឡាយក្នុងពេលអនាគតបានយ៉ាងត្រឹមត្រូវ និងកាន់តែសមស្របន្តិចម្តងៗ ហើយអាចដឹកនាំជីវិត ឱ្យដើរឆ្ពោះទៅរកជោគជ័យ ទាំងក្នុងជាកជីវិតបុគ្គលខ្លួនឯងព្រមទាំងភាពរីកចម្រើនរីងមាំរបស់មនុស្សជាតិផងដែរ។

ផ្ទុយទៅវិញ **"ការមិនបានរៀន"** វានឹងនាំមនុស្សឱ្យធ្លាក់ទៅក្នុងស្ថានភាពដុនដាបដោយសារតែ **"ការសម្រេចចិត្តខុស"**. ដោយសារតែដំណើរជីវិត ពុំមានការយល់ដឹងឱ្យបានជ្រៅជ្រះ មិនបានចាប់ភ្លឹកទៅលើការបេះបត់បែនឱ្យបានសមស្រប ហើយជាញឹកញាប់ ការមិនបានរៀនអ្វីៗវានាំទៅរកការប្រព្រឹត្តខុសហើយខុសទៀត ខុសដដែលៗ ដែលយើងគួរតែបានកែលម្អវាចាប់តាំងពីពេល[illegible]មកម៉្លេះ

ដោយហេតុនេះ ទើបយើងអាចនិយាយបានថា

www.facebook.
Fb : Entertainm

*"ការរៀនយល់ដឹង" គឺជាចំណុចចាប់ផ្តើមនៃដំណើរឆ្ពោះទៅរក "ភាពជោគជ័យ" ក្នុងឆាកជីវិតរបស់មនុស្ស។*

*"ការមិនបានរៀន" គឺជាចំណុចចាប់ផ្តើមនៃដំណើរឆ្ពោះទៅរក "ទីអវសាន" ក្នុងឆាកជីវិត។*

### ✿ "ការមិនបានរៀន" ជាចំណុចចាប់ផ្តើមនៃ "ក្តីលិចលង់"

*"បុគ្គលដែលនៅស្ងៀម នឹងត្រូវគេបំភ្លេច*
*បុគ្គលដែលមិនរុលទៅមុខ នឹងត្រូវនៅពីក្រោយ*
*បុគ្គលដែលនៅត្រេតត្រត នឹងត្រូវគេដើរចោល តាមគេមិនទាន់*
*អ្នកដែលមិនរីកដុះដាល នឹងត្រូវស្វិតក្រៀមស្រពោន*
*អ្នកដែលដកថយ គឺជាអ្នកចាញ់*
*សភាវៈដែលមិនកម្រើក គឺជាចំណុចចាប់ផ្តើមនៃក្តីលិចលង់"* ។

នេះគឺសច្ចធម៌របស់មនុស្សជាតិ ដែលគេបានពិសោធរួចមកហើយ នៅទូទាំងសកលលោក ដូចគ្នាទៅនឹងច្បាប់ទីពីររបស់ "ទែរម៉ូឌីណាមិច" ដែលបានចែងថា **វត្ថុទាំងឡាយដែលត្រូវគេទុកចោល ដោយពុំបានថែរក្សា ពុំបានពង្រីកស្ថាបនា ពុំបានយកទៅប្រើប្រាស់ឱ្យសក្តិសមទៅតាមស្ថានភាពរបស់វាទេ វត្ថុនោះនឹងត្រូវចុះទ្រុឌទ្រោមនៅទីបំផុត។**

ភាពខុសគ្នាវានៅត្រង់ថា ច្បាប់របស់ទែរម៉ូឌីណាមិច គឺជាអ្វីដែលគេអាចពិសោធឱ្យឃើញជាក់ស្តែងបានច្បាស់លាស់ហើយលឿនរហ័សទៀតផង ដូចជា ដុំសាច់ដែលគេដាក់ចោល វានឹងស្អុយខូចក្នុងរយៈពេលដ៏ខ្លី រថយន្តដែលគេចតទុកចោលយូរបន្តិច ម៉ាស៊ីនរបស់វានឹងចាប់ផ្តើមដើរមិនសូវស្រួល ផ្ទះដែលពុំមាន[illegible] ស្រមេកស្រមក ទ្រុឌទ្រោមដ៏មិនគួរឱ្យជឿ។

www.facebook.
Fb : Entertainm

## *" ការមិនបានរៀន នាំមនុស្សឲ្យឈានទៅរកក្តីវិបត្តិ "*

កាលបើពិចារណាទៅលើបុគ្គលម្នាក់ៗ ស្ថាប័ន អង្គភាព ឬសង្គមដែលមិនដើរទៅមុខ ពុំមានការអភិវឌ្ឍន៍ លទ្ធផលនៃការចុះអន់ថយទ្រុឌទ្រោម អាចឱ្យយើងសង្កេតឃើញយ៉ាងយឺតៗ និងពុំសូវច្បាស់ប៉ុន្មានទេក្នុងរយៈពេលដ៏ខ្លីដិបូងៗ រហូតដល់យើងមិនអាចទាំងដឹងថា តើវានឹងមានអ្វីកើតឡើងនោះឡើយ។ តែបើពេលវេលាកន្លងទៅកាន់តែយូរ លទ្ធផលនឹងបង្ហាញឱ្យឃើញកាន់តែច្បាស់ ហើយកាន់តែធ្ងន់ធ្ងរជាលំដាប់ផងដែរ រហូតដល់ពេលខ្លះវាក្លាយទៅជា **"ហួសពេល កែលែងឡើង"** ចំពោះអ្វីៗដែលបានបាត់បង់ទៅនោះទៀតផង។

## ✿ **"សកលភាវូបនីយកម្ម" គាបសង្កត់ឱ្យមនុស្សត្រូវតែរៀន**

"សកលភាវូបនីយកម្ម" បានបង្កើតជាចរន្តផ្លាស់ប្តូរបត់បែន ដែលចាំសង្វើញសង្គមលោកយើងគ្រប់វិនាទី។ ចំណេះដឹង បច្ចេកវិទ្យា វប្បធម៌របស់តំបន់នីមួយៗ បានបង្ហូរដាក់គ្នាទៅវិញទៅមកគ្រប់ពេលវេលា ធ្វើឱ្យកើតមានទំនាក់ទំនងរវាងគ្នានឹងគ្នាយ៉ាងជិតស្និទ្ធ ដែលមិនធ្លាប់មានពីមុន។ អ្វីដែលកើតឡើងក្នុងតំបន់មួយនៃពិភពលោក មានផលប៉ះពាល់ដល់តំបន់ផ្សេងៗទៀតដែលស្ថិតនៅយ៉ាងឆ្ងាយពីគ្នារាប់ពាន់រាប់ម៉ឺនគីឡូម៉ែត្រ។ ភាពលឿនរហ័ស និងឥទ្ធិពលដ៏គ្មានព្រំដែនទាំងនេះ បានធ្វើឱ្យមានការផ្លាស់ប្តូរជាអតិបរមាទៅលើគ្រប់ជីវិត គ្រប់ស្ថាប័ន គ្រប់អង្គភាព គ្រប់សង្គមទាំងលើផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គម។ អ្វីទាំងនេះ គឺដោយសារតែពុំមានស្ថាប័នឬសង្គមណានៅដាច់[illegible] ដូច្នេះ ទើបគេមិនអាចគេចផុតពីចរន្តនៃការផ្លាស់ប្តូរនេះបានឡើយ។

www.elibraryofcambodia.org www.facebook. Fb : Entertainm

### *“ សកលភាវូបនីយកម្ម ជាចរន្តបក់បែនដែលរុញ សង្រ្គោញសង្គមលោកឲ្យរំកិលទៅមុខគ្រប់វិនាទី ”*

បុគ្គល ស្ថាប័ន សង្គម ឬអង្គភាពណាដែលរចេះបត់បែនផ្លាស់ប្ដូរទៅតាមរបត់នៃការប្រែប្រួលរបស់លោកយើងបាន គេនឹងអាចដឹកនាំខ្លួនឲ្យសម្រេចជោគជ័យ ព្រមទាំងរក្សាបាននូវភ្លឹចម្រើនរុងរឿងរបស់ខ្លួនតទៅមុខ។ ផ្ទុយទៅវិញ បើបុគ្គល ស្ថាប័ន ឬសង្គមដែលនៅទ្រឹងមួយកន្លែង មិនព្រមយកចិត្តទុកដាក់អំពីសារៈសំខាន់នៃការបត់បែន ឬមិនអាចកែសម្រួលខ្លួនឯងឲ្យស៊ីសង្វាក់ជាមួយចរន្តសកលភាវូបនីយកម្ម (Globalization)[1] ទេនោះ អ្នកនោះនឹងត្រូវគេទុកឲ្យនៅពីក្រោយខ្នង ហើយបានត្រឹមតែសម្លឹងមើលពីជោគជ័យ និងភាពរីកចម្រើនរបស់អ្នកដទៃដោយក្ដីឈឺចាប់តែប៉ុណ្ណោះ។

ដើម្បីបត់បែនផ្លាស់ប្ដូរឲ្យទាន់ចរន្តនៃសកលភាវូបនីយកម្មដ៏គ្មានព្រំដែន ឲ្យបានស៊ីសង្វាក់ ហើយឲ្យទាន់សភាពការណ៍នោះ យើងចាំបាច់ត្រូវមានគុណសម្បត្តិពិសេសម្យ៉ាងគឺ “**ការរៀនយល់ដឹង**” នោះឯង។

ការរៀន នាំឲ្យយើងយល់ដឹងអំពីសភាពការណ៍ដែលខ្លួនកំពុងប្រព្រឹត្តនិងកំពុងប្រឈមមុខ ឲ្យយើងបានស្វែងយល់អំពីដំណើរការផ្សេងៗលើពិភពលោក អំពីសង្គម និងអំពីគូប្រជែង ឲ្យយើងបានយល់ដឹងពីចំណេះវិជ្ជានិងបច្ចេកវិទ្យាថ្មីៗ ទទួលបាននូវទិន្នន័យ ពត៌មាន ដែលមានសារៈ-

(1) សកលភាវូបនីយកម្ម : ការរីករាលដាលទូទាំងពិភពលោក ការដែលមនុស្សជាតិទូទាំងសកលលោក ទាក់ទងផ្សារភ្ជាប់ជាមួយគ្នាបាន ឬការមានផលប៉ះពាល់រវាងគ្នាយ៉ាងឆាប់រហ័ស ហា[illegible] ដោយ[illegible]ការ[illegible]ទំនង ដ៏ឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ (ពន្យល់សាកល្បង)

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

សំខាន់ដល់ការប្រមើលស្ថានការណ៍ ស្ថាបស្ទង់ដើម្បីងាយស្រួលសម្រេចចិត្ត រៀនសូត្រអំពីកំហុសច្គង រៀនអំពីការដួលរលំពីអតីតកាល ដើម្បីកែសម្រួលខ្លួនឱ្យរីកចម្រើនទៅរកផ្លូវល្អ។ ហេតុនេះ ការរៀនគឺជាចម្លើយសម្រាប់ការស្វែងរកជោគជ័យរបស់បុគ្គល អង្គភាព ស្ថាប័ន និងគ្រប់សង្គមទាំងឡាយ រហូតដល់យើងអាចនិយាយបានថា

*" នៅលើលោកបច្ចុប្បន្ន ពុំមានអ្នកណាអាចឈរយ៉ាងរឹងប៉ឹង ឬសម្រេចជោគជ័យបានឡើយ ប្រសិនបើគេមិនបានរៀន "*

## ✿ ភាពល្បីងល្បូមចត់នៃការ "ចេះមិនដល់" ឬ "ចេះស្ទើរ"

អ្វីដែលយើងបាននិយាយពីខាងលើគឺ ការរៀនជាគន្លឹះដ៏សំខាន់ក្នុងការស្វែងរកជោគជ័យ ហើយផ្ទុយទៅវិញ "ការចេះមិនដល់" គឺជាដំណើរឆ្ពោះទៅរកភាពដុនដាបនិងក្តីវិបត្តិផ្សេងៗ។ បទពិសោធន៍របស់ក្រុមហ៊ុនធំៗ ឬអ្នកដឹកនាំមួយចំនួន បានទុកជាឧទាហរណ៍សម្រាប់ដាស់តឿនឱ្យយើងបានឃើញផលល្អនិងផលអាក្រក់ដោយឡែកៗពីគ្នា អំពីរឿងទាំងនេះ។

*" យើងត្រូវស្វែងយល់ពីកំហុសឆ្គងនិងការថ្ងោះធ្លោយពីអតីត ដើម្បីកែលម្អ ស្ថាបនាខ្លួនឱ្យបានរីកចម្រើន "*

## ✇ *ក្រុមហ៊ុន ដិកខា រីខរឌិង* (Decka Recording)

លោកអ្នកមួយចំនួនអាចនឹងធ្លាប់ស្គាល់វង់តន្ត្រី "ដឺប៊ីថឺល" បានយ៉ាងច្បាស់ ព្រោះពួកគេ (The Betles) គឺជាក្រុម[illegible]មួយ[illegible] ក្រុមក្មេងដែលទទួលជោគជ័យខ្ពស់បំផុត ជារៀងរហូតតមក។ ពួកគេបាន

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

សាងប្រវត្តិសាស្ត្រមួយថ្មីដល់មុខមាត់វង់តន្ត្រីលោក និងជាប់ជាប្រវត្តិមួយដែលត្រូវចោទជាសំណួរអស់រយៈពេលដ៏យូរអង្វែង។ ការស់សែតនិងថាសចម្រៀងរបស់ពួកគេ ត្រូវគេប៉ាន់ប្រមើលមើលថា លក់បានរាប់រយលានដុំចាប់តាំងពីអតីតកាលមកទល់បច្ចុប្បន្ន។ ផលប្រយោជន៍ដ៏មហាសាលនេះបានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ក្រុមហ៊ុន **អ៊ី អឹម អាយ** ( EMI ) អស់រយៈកាលដ៏យូរអង្វែង ទន្ទឹមនឹងក្រុមហ៊ុន **ដិកខា រីខរឌិង** ជាក្រុមហ៊ុនដែលពួក **ប៊ីថឺល** បានទៅសម្ដែងឲ្យគេមើលនៅក្នុងឆ្នាំ១៩៦២ ប៉ុន្តែលោក **ឌិក រ៉ូវ** ជានាយកគ្រប់គ្រងក្រុមហ៊ុននោះ បែរជាមើលមិនឃើញពីគុណសម្បត្តិរបស់យុវតន្ត្រីករសក់វែងទាំងបួននាក់នេះទាល់តែសោះ។ គេនិយាយទៅកាន់លោក **ប្រៃអាន់ អែបស្តាញន៍** ដែលជាអ្នកគ្រប់គ្រងក្រុមភ្លេង ដឹប៊ីថឺល ថា

*"ក្រុមភ្លេងដែលកាន់តែហ្គីតាបែបនេះ វាហួសសម័យទៅហើយ"*

ទោះបីជា អែបស្តាញន៍ ខំអង្វរករឲ្យក្រុមហ៊ុន ដិកខា រីខរឌិង ពិចារណាសាជាថ្មីម្ដងទៀត ព្រមទាំងសន្យាថា ពួកគេនឹងទិញថាសចម្រៀងរបស់ដឹប៊ីថឺលក្នុងមួយឈុត ៣០០០ដុំ គ្រប់ឈុតទាំងអស់យ៉ាងណាក៏ដោយ ក៏នាយកគ្រប់គ្រងក្រុមហ៊ុន ដិកខារីខរឌិង នៅតែមិនខ្វល់អើពើអ្វីទាំងអស់។ ទីបំផុត អែបស្តាញន៍ បានទៅទាក់ទងជាមួយក្រុមហ៊ុន អ៊ី អឹម អាយ ហើយបានព្រមព្រៀងចុះកិច្ចសន្យា សហការថតបទភ្លេងជាមួយគ្នាប្រកបដោយជោគជ័យ។

លទ្ធផលដែលកើតឡើងគឺ ក្រុមហ៊ុន អ៊ី អឹម អាយ បានទទួលផលកម្រៃមានតម្លៃរហូតដល់រាប់ពាន់លានដុល្លារ ហើយនៅឈរបានយ៉ាងរឹងប៉ឹងរហូតមកដល់សព្វថ្ងៃ។ ចំណែកក្រុមហ៊ុន ដិកខា រីខរឌិងវិញ ពុំមានអ្នកណាគេស្គាល់ទៀតឡើយក្នុងសម័យបច្ចុប្បន្ននេះ។

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

នេះគឺជារឿងដ៏គួរឱ្យសោកស្ដាយ ប្រសិនបើអ្នកគ្រប់គ្រងក្រុមហ៊ុន ជិកខា រីខរខិង ខិតខំរៀនស្វែងយល់ និងចេះប្រមើលមើលអំពីចរន្តនិយមខាងធ្យូតន្ត្រីឱ្យបានត្រឹមត្រូវ គេមុខជាមិនធ្លាក់ចូលក្នុងគន្លងនៃផ្លូវខុសច្លោះធ្លោយដ៏ធ្ងន់ធ្ងរបែបនេះឡើយ។

## *ក្រុមហ៊ុនទូរលេខវីសធើនយូញៀន* (Western Union)

**អាឡិចសានឌ័រ គ្រេហេម បេលល៍** *ជាអ្នកគិតច្នៃប្រឌិតរកឃើញអំពីទូរស័ព្ទនៅក្នុងឆ្នាំ១៨៧៦។ ដោយសារតែវាជារបស់ថ្មីក្នុងសម័យនោះ ទើបពុំសូវមានអ្នកណាចាប់អារម្មណ៍ទៅលើវាឡើយ។ ឯអ្នករកស៊ីធំៗ ក៏មិនបានផ្ដល់សារៈសំខាន់ដល់របស់ច្នៃប្រឌិតថ្មីនេះប៉ុន្មានដែរ ដែលជាហេតុធ្វើឱ្យក្រុមហ៊ុន* **បេលល៍ តេឡេហ្វូន** *របស់លោក* **គ្រេហេម បេលល៍** *ត្រូវខាតបង់យ៉ាងធ្ងន់ធ្ងររហូតដល់សុំលក់ "ច្បាប់រក្សាសិទ្ធិទូរស័ព្ទ" ទាំងអស់ឱ្យទៅក្រុមហ៊ុន* **វីសធើន យូញៀន** *ជាក្រុមហ៊ុនដ៏ធំ ដែលកំពុងរកស៊ីផ្នែកទូរលេខក្នុងតម្លៃ ១០០.០០០ ដុល្លារ តែវីសធើនយូញៀនបែរជាមិនចាប់អារម្មណ៍ ហើយយល់ឃើញថា វត្ថុច្នៃប្រឌិតនេះវាគ្រាន់តែជា*

*"ល្បែងលេងពីអគ្គិសនីដ៏ឥតប្រយោជន៍តែប៉ុណ្ណោះ"*៥

*ប៉ុន្មានឆ្នាំក្រោយមក* **វីសធើន យូញៀន** *បានប្ដូរចិត្តមកវិញ។ គេរកទៅទិញ "ឯកសិទ្ធិ" នូវឧបករណ៍ដែលមានលក្ខណៈស្រដៀងគ្នានេះពីលោក* **ថូម៉ាស់ អាល់វ៉ា អេឌីសាន់** *តែត្រូវក្រុមហ៊ុន* **បេលល៍** *ប្ដឹងពីបទល្មើសនឹងច្បាប់រក្សាសិទ្ធិ ហើយបេលល៍បានឈ្នះក្ដីនោះ។ ទីបំផុត* **វីសធើន**

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

**យូញៀន** ត្រូវដកខ្លួនថយចេញពីមុខជំនួញទូរស័ព្ទ។ ថ្ងៃក្រោយមកទៀត ទូរស័ព្ទ ត្រូវបានគេនិយមចូលចិត្តយ៉ាងសុសសាយទូទាំងសហរដ្ឋអាមេរិក ទ្វីបអឺរ៉ុប និងគ្រប់ទិសទីពេញទាំងសកលលោក។

**ការដែល វីសធើន យូញៀន ត្រូវបាត់បង់ឱកាសមាសរបស់ខ្លួន ក៏ដោយសារតែពួកគេបិទទ្វារចិត្តរបស់ខ្លួន មិនព្រមរៀនស្វែងយល់ពីអ្វីថ្មីៗ ក្នុងពេលនោះឯង។**

## *ក្រុមហ៊ុន រេមិងតុន អាមស៍*

ក្នុងឆ្នាំ១៨៩៧ ក្រុមហ៊ុនផលិតឧបករណ៍វាយអង្គលីលេខ **ដឹកណាំ** បានសុំលក់ឯកសិទ្ធិឧបករណ៍វាយអង្គលីលេខឲ្យក្រុមហ៊ុន **រេមិងតុន អាមស៍** តែប្រធានក្រុមហ៊ុននេះបែរជាបដិសេធមិនរវីរវល់ ព្រមទាំងពោលថា

> *" គ្មានឧបករណ៍ប្រើប្រាស់ប្រភេទណា ដែលអាចយកមកជំនួសស្មៀនដ៏ស្មោះត្រង់និងទុកចិត្តបានឡើយ "*

ប៉ុន្តែអ្នកគ្រប់គ្រងក្រុមហ៊ុន **អាន់ឌវ៉ូត** គេពុំបានគិតដូច្នេះទេ។ គេមើលឃើញថា ទៅថ្ងៃមុខ ឧបករណ៍វាយអង្គលីលេខនឹងមានតួនាទីដ៏សំខាន់សម្រាប់ការងារនៅតាមការិយាល័យផ្សេងៗ។ ក្រុមហ៊ុននេះ បានទាក់ទងសុំទិញឯកសិទ្ធិឧបករណ៍វាយអង្គលីលេខពីក្រុមហ៊ុន **ដឹកណាំ** ហើយអ្វីដែលគេរំពឹងទុក ក៏បានក្លាយជាការពិត។ រយៈពេល ៥០ឆ្នាំ ក្រោយមក ឧបករណ៍វាយអង្គលីលេខ អា[illegible] គ្រឿង នេះជាបទពិសោធន៍មួយដែលបញ្ជាក់ឲ្យឃើញថា ការខាតបង់មួយចំនួន

www.facebook.
Fb : Entertainm

បណ្តាលមកពីកំហុសច្ឆន្ទរបស់បុគ្គលឬស្ថាប័នដែលបិទខ្លួនឯង មិនព្រមស្វែងយល់ពីអ្វីថ្មីៗនៅកណ្តាលចរន្តបត់បែននៃសង្គមលោក ហើយម្យ៉ាងទៀតវាក៏ច្ឆុះបញ្ជាំងឱ្យឃើញដែរថា ជោគជ័យដ៏ធំធេងរបស់បុគ្គល ស្ថាប័ន ឬអង្គភាពផ្សេងៗ បានមកពីការបើកចំហចិត្តទទួលរៀនសូត្រទៅតាមរបត់របស់ពិភពលោកយើងនេះឯង។

## *ក្រុមរបស់ប៉ុលពត*

**"ការចេះមិនដល់"** មួយចំនួន វាមានការប៉ះពាល់ចំពោះបុគ្គលខ្លួនឯង ឬចំពោះក្រុមមួយចំនួនតូចរបស់ខ្លួនតែប៉ុណ្ណោះ ប៉ុន្តែ **"ការចេះស្ទើរ"** ឬ **"ការចេះមិនដល់"** ខ្លះទៀត វាបានធ្វើឱ្យប៉ះពាល់ដល់មនុស្សចំនួនច្រើន ឬប៉ះពាល់ដល់វាសនាប្រទេសជាតិទាំងមូលក៏មានដែរ។

ការដែលចេះតែម្នាក់ឯង មើលទៅលើស្ថានការណ៍តែមួយជ្រុងយ៉ាងងប់ងល់ ឃើញតែវណ្ណៈអធន ឃើញតែការប្រើកម្លាំងកាយនិងចិត្ត ឃើញតែអ្វីដែលនៅចំពោះមុខ ប៉ុលពត មិនទទួលស្គាល់ការជជែកជកញែក មិនទទួលស្គាល់អ្នកចេះដឹង មិនទទួលស្គាល់កម្លាំងប្រាជ្ញា មិនទទួលស្គាល់នូវភាពជាមនុស្ស យកមនុស្សអវិជ្ជាឱ្យគ្រប់គ្រងជាន់ឈ្លីលើអ្នកចេះដឹង... និយាយដោយឡូម ក្រុមរបស់ប៉ុលពត មុជក្បាលទៅលើទ្រឹស្តីរបស់ក្រុមមួយតែគេមិនព្រមបើកភ្នែកមើល និងមិនព្រមរៀនពីអ្វីល្អៗដែលកន្លែងដទៃផ្សេងទៀតគេមាននោះឡើយ។

**ការ "ចេះមិនដល់" របស់ក្រុមប៉ុលពត [illegible] និងវិនាសកម្មដ៏ធំធេងដល់ប្រទេសជាតិ និងប្រជាជនកម្ពុជា។**

www.facebook.
Fb : Entertainm

* តាមឧទាហរណ៍ខាងលើ យើងសង្កេតឃើញថា កំហុសច្គង់ ឬ ការថ្លោះធ្លោយរបស់អង្គការ ឬក្រុមហ៊ុនជំនួញទាំងនោះ សុទ្ធតែមាន មូលហេតុមកពីការ **យល់មិនបានស៊ីជម្រៅ ( យល់ស្ទើរ )** ពោលគឺ

*ខ្វះការយល់ដឹងឲ្យបានគ្រប់គ្រាន់ ដើម្បីសម្រេចចិត្តឲ្យបានត្រឹមត្រូវនោះឯង។*

អ្វីទាំងនេះ ដោយសារកង្វះខាតអំពីការយកចិត្តទុកដាក់ស្វះស្វែង សិក្សាស្រាវជ្រាវរកព័ត៌មានសម្រាប់យកមកស្ទាបស្ទង់ វាយតម្លៃ ប្រមើល មើលពីស្ថានការណ៍ឱ្យបានល្អិតល្អន់ ទើបធ្វើឱ្យមានការសម្រេចចិត្តខុស ដែលជាប្រការគួរឱ្យសោកស្តាយបំផុត។

**ពេលខ្លះការសម្រេចចិត្តខុសតែម្តងគត់ វាក៏ជាការគ្រប់គ្រាន់ហើយ ក្នុងការធ្វើឱ្យជីវិតផ្ទាល់ខ្លួន ក្រុមហ៊ុន ឬប្រទេសជាតិត្រូវជួបនឹងក្តីវិបត្តិ ឬក្តីវិនាសអន្តរាយដ៏ធំធេងទាំងនោះ។**

**ស្នេហាជាតិ + ចេះស្ទើរ (ល្ងង់) ⇒ ថយក្រោយ ឬវិនាសអន្តរាយ**

នេះជាមេរៀនដែលយើងត្រូវតែចងចាំ។ យើងជឿថា បងប្អូនខ្មែរ គ្រប់គ្នាសុទ្ធតែជាអ្នកស្នេហាជាតិ។ តែអ្វីដែលយើងត្រូវភ័យ គឺការបិទខ្លួនឯង អួតខ្លាំង អួតឆ្លាត អាត្មានិយម អញ្ញនិយមនោះឯង ដែលនាំឱ្យយើងធ្លាក់ ចូលក្នុងរណ្តៅគ្រោះថ្នាក់ ហើយទីបញ្ចប់ ក៏បន្ទោសដាក់គ្នាអែអញ្ចឹងទៅ។

⇨⇨⇨

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

## ✿ ស្ពានញញឹមនៃជោគជ័យ

**"ការរៀន" គឺជាផ្លូវឆ្ពោះទៅរកជោគជ័យ។** បុគ្គល ស្ថាប័ននានា ឬសង្គមណាដែលយកចិត្តទុកដាក់ក្នុងការរៀនសូត្រ មិនទៅទ្រឹងមួយកន្លែង ពុះពារកសាងខ្លួនឱ្យដើរទៅមុខជាប្រចាំ គេមុខជាបានសម្រេចជោគជ័យនៅថ្ងៃមុខជាប្រាកដ។

## *រឿងនិទានរបស់ យ៉ាហ៊ូ (YAHOO!)*

នេះជារឿងនិទានរបស់និស្សិតពីរនាក់ ដែលបានជាប់សញ្ញាប័ត្របណ្ឌិតផ្នែកវិស្វករអគ្គិសនី ពីមហាវិទ្យាល័យ **ស្ដេនហ្វត** សហរដ្ឋអាមេរិក។ គេទាំងពីរនាក់គឺ **ដេវិដ ហ្វ៊ីឡូ** និង **ជើរី យ៉ាង** *(ជាជនជាតិកូរ៉េខាងត្បូង)*។

ពួកគេចូលចិត្តស្រាវជ្រាវព័ត៌មានផ្សេងៗពីក្នុងប្រព័ន្ធអ៊ិនធើណេត។ គេបានកត់សម្គាល់ឃើញថា ទិន្នន័យដ៏ច្រើនសន្ធឹកសន្ធាប់ទាំងឡាយនោះ ពុំទាន់បានរៀបចំឱ្យស្រួលបួលតាមលំដាប់លំដោយនៅឡើយទេ។ នៅក្នុងខែមេសាឆ្នាំ១៩៩៤ ពួកគេបានចាប់ផ្ដើមចំណាយពេលវេលារបស់ខ្លួនក្នុងការរៀបចំទិន្នន័យទាំងនោះឱ្យមានជាលំដាប់ ជាក្រុម និងប្រមូលផ្ដុំទុកនៅក្នុងគេហទំព័រ (Home page) ដែលគេឱ្យឈ្មោះថា " YAHOO! " នោះឯង។ លទ្ធផលជាក់ស្ដែងបានឱ្យយើងឃើញថា អ្នកដែលប្រើអ៊ិនធើណេតពាសពេញទាំងសកលលោក បានបើកចូលមើលក្នុងទំព័ររបស់គេ ដោយមកពីវាមានភាពងាយស្រួលក្នុងការស្វែងរកទិន្នន័យផ្សេងៗ ដែលអ្វីទាំងនេះ កើតឡើងដោយការស្រឡាញ់ចូលចិត្ត និងការយកចិត្តទុកដាក់ ទើបធ្វើឱ្យពួកគេបង្កើតបានទៅជាមុខជំនួញមួយដែលមានទំហំប្រាក់ចំណូលរាប់លានដុល្លារ។ ចំណូលរបស់ពួកគេ បានមកពីការលក់ទំព័រឃោសនាឱ្យដល់ក្រុមហ៊ុនជំនួញផ្សេងៗ ដែល

www.facebook.
Fb : Entertainm

នាំយកមុខទំនិញរបស់ខ្លួនមកចុះផ្សាយក្នុងគេហៈទំព័ររបស់យ៉ាហ៊ូនោះឯង។

ក្រៅពីនេះ ពួកគេនៅបានទទួលប្រាក់ចំណូលបន្ថែម ដោយការលក់ផលិតផលផ្សេងៗដែលដាក់ផ្លាកយីហោ " យ៉ាហ៊ូ " ទៀតផង។

ពេលដែល **ជើរី យ៉ាង** ធ្វើដំណើរវិលត្រឡប់មកកូរ៉េខាងត្បូងដែលជាប្រទេសកំណើតរបស់ខ្លួន គេត្រូវបានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់ប្រធានាធិបតីនិងប្រជាជនកូរ៉េ ប្រៀបដូចជាវីរបុរសរបស់ជាតិម្នាក់ដូច្នោះដែរ។ ដោយគជ័យដ៏ធំធេងអស្ចារ្យរបស់គេព្រមទាំងមិត្តភក្តិ កើតឡើងដោយការរៀនសូត្រ បត់បែន សម្របទៅតាមដំណើរការផ្លាស់ប្តូររបស់ពិភពលោកយើងនោះឯង។

* * *

☞ *"ជោគជ័យ" មិនមែនជារបស់បានមកដោយងាយនោះទេ*
*តែវាកើតឡើងដោយញើសឈាមនៃការរៀនសូត្រ។*
*ហេតុនេះ បើអ្នកណាចង់បានវា អ្នកនោះត្រូវតែខស្វាហ៍*
*ព្យាយាមរៀនសូត្រស្វែងយល់ពីអ្វីផ្សេងៗ*
*រៀនដោយមិនធុញទ្រាន់ មានស្មារតីភ្ញាក់រឭកជាប្រចាំ*
*ដើរឆ្ពោះទៅរកគោលដៅនៅខាងមុខ។*
*នោះ គឺជាជោគជ័យដ៏មានរសជាតិឈ្ងុយឆ្ងាញ់*
*និងបើអ្នកណាមិនបានស្វែងយល់រៀនសូត្រជាប្រចាំទេនោះ*
*គេពិតជាមិនបានភ្លក់រសជាតិនេះពិតប្រាកដឡើយ។*

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

**អ្វីដែលអ្នកចេះក្នុងថ្ងៃនេះ វានឹងហួសសម័យក្នុងថ្ងៃស្អែក**
**បើអ្នកឈប់រៀនសូត្រ អ្នកនឹងត្រូវតាំងនៅមួយកន្លែង។**

What we know today will be obsolete tomorrow.
If we stop learning we stagnate.

**ដូរ៉ូធី ប៊ីល្លិងតុន - Dorothy D. Billington**

Adults Who learn and Grow
( In New Horizons for Learning, Spring 1993. )



www.elibraryofcambodia.org
www.facebook.
Fb : Entertainm

ការរៀនស្វែងយល់ មិនមែនសុទ្ធតែបានពីការបង្រៀនទាំងអស់ទេ
ភាគច្រើនវាកើតឡើងដោយ
ការបានចូលរួមក្នុងសកម្មភាពផ្សេងៗយ៉ាងមានឥស្សរភាព
និងប្រកបដោយអត្ថន័យនោះឯង។

Most learning is not the result of instruction.
It is rather the result of unhampered participation,
in a meaningful setting.

**អ៊ីវ៉ាន អ៊ីលិច - Ivan Illich**
Deschooling Society, 3, 1970.



www.elibraryofcambodia.org
www.facebook.
Fb : Entertainm

# ២

## ដំណើរការនៃ "ការរៀន"

ការរៀនគឺជា "ដំណើរការ" ដែលបុគ្គលម្នាក់ចាប់ផ្ដើមដោយការបើកចំហចិត្តទទួលព័ត៌មានឬចំណេះដឹងអ្វីមួយ យកមកគិត ត្រិះរិះ វិភាគ ពិចារណា បកស្រាយព័ត៌មានទាំងនោះរហូតយល់បានក្នុងជម្រៅចិត្ត ដែលព័ត៌មាន(ឬចំណេះដឹង)មួយចំនួន អាចធ្វើឱ្យមានការផ្លាស់ប្ដូរទស្សនៈ ឬមានការយល់ឃើញនៅក្នុងចិត្ត និងបង្កឱ្យកើតមានជាទង្វើឬការប្រព្រឹត្ត ស្ដែងចេញមកខាងក្រៅ។ ឯចំណែកព័ត៌មាន ឬចំណេះដឹងប្រភេទខ្លះ អាចឱ្យគេយកទៅអនុវត្តប្រើប្រាស់ ឬ្លោះទៅរកភាពរីកចម្រើនជាបន្តទៅមុខថែមទៀតផងដែរ។

✿ **ការរៀន គឺជា "ដំណើរការ"**

www.elibraryofcambodia.org www.facebook.

ពាក្យថា "ដំណើរការ" (Process) មានន័យសំដៅទៅលើ

Fb : Entertainm

**កម្មវិធីឬលំដាប់នៃការប្រព្រឹត្ត ដែលមានដំណើរទៅមុខជាបន្តបន្ទាប់ រហូតដល់សម្រេចបានលទ្ធផលក្នុងកម្រិតណាមួយ** ដូចជា ដំណើរការសាងសង់ផ្ទះ ដែលគេត្រូវគូសប្លង់ បុកគ្រឹះ រៀបផ្ដឹម ចាក់សសរ រៀបឥដ្ឋ ចាក់ប្លង់សេ រហូតដល់ការលាបថ្នាំ រៀបចំតុបតែងជាបន្តបន្ទាប់រហូតដល់ទីបញ្ចប់។

ឯដំណើរការរៀន ក៏មានវគ្គមានឃ្នាច្រើនដូចគ្នាដែរ និងប្រសិនបើខ្វះខាតដំណាក់កាលណាមួយ ដំណើរការរៀននោះ ក៏នឹងមិនសូវបានពេញលក្ខណៈសម្រាប់យកទៅអនុវត្តប្រើប្រាស់ឲ្យបានល្អឡើយ។ ផ្ទុយទៅវិញ បើដំណើរការនៃការរៀន ប្រព្រឹត្តទៅតាមលំដាប់លំដោយ មិនរាំងស្ទះនៅកណ្ដាលផ្លូវទេនោះ យើងអាចចាត់ទុកថា ជាការរៀនពេញលក្ខណៈហើយ គេអាចយកអ្វីដែលរៀននោះ ទៅប្រើឲ្យកើតជាប្រយោជន៍ ឬធ្វើឲ្យកើតមានជាសកម្មភាពដែលនាំឲ្យមានការប្រែប្រួលផ្លាស់ប្ដូរ ល្អប្រសើរជាងមុន។

> “ *ដំណើរការរៀនក៏មិនខុសគ្នាពីដំណើរការអ្វីផ្សេងៗដែរ*
> *បើខ្វះខាតដំណាក់កាលណាមួយ*
> *ដំណើរការរៀននោះ នឹងមិនបានពេញលក្ខណៈឡើយ* ”

ហេតុនេះ ការរៀនពិតប្រាកដ មិនមែនបុគ្គលម្នាក់ៗគ្រាន់តែទទួលយកចំណេះមកដាក់ក្នុងខួរក្បាលប៉ុណ្ណោះទេ តែវាត្រូវឆ្លងកាត់ដំណាក់កាលសំខាន់ៗផ្សេងៗជាច្រើន ទើបអាចចាត់ទុកថា ជាការរៀនពិតប្រាកដបាន។

www.elibraryofcambodia.org

យើងនឹងពិចារណាអំពីដំណើរការរៀនទៅតាមវិធីខាងក្រោម ៖

www.facebook.
Fb : Entertainm

## ✿ ដំណើរការនៃការរៀន

### ➻ *ដំណាក់កាលទី១ : បើកចំហចិត្ត ទទួលយកចំណេះដឹង*

"**ចិត្ត**" គឺជាចំណុចចាប់ផ្ដើម ដែលនាំទៅដល់ការប្រព្រឹត្តផ្សេងៗ ប្រៀបដូចមេទឹក ដែលជាប្រភពនៃទឹកស្ទឹងទន្លេទាំងឡាយដូច្នោះដែរ។

ដំណើរការរៀនមានប្រភពមកពី "ចិត្ត" ។ វាកើតឡើងបាន លុះត្រាតែយើង "បើកចំហ" ទទួលយកចំណេះដឹងអ្វីៗចូល។ ចំណេះដឹងទាំងឡាយនោះមានដូចជា ក្បួនតម្រា មុខវិជ្ជាសម្រាប់ប្រកបអាជីពផ្សេងៗ បច្ចេកវិទ្យាថ្មីៗ ពាក្យប្រដៅដាស់តឿនរបស់អ្នកនៅជុំវិញ ខ្លឹមសារល្អៗនៅក្នុងសៀវភៅអានឬនៅក្នុងខ្សែភាពយន្ត ព័ត៌មានផ្សេងៗក្នុងទំព័រកាសែត ការវិភាគជក់ញែកនៅក្នុងកម្មវិធីវិទ្យុ ឬទូរទស្សន៍ជាដើម...។ល។

ពាក្យថា "**បើកចំហចិត្ត**" មានន័យថា បុគ្គលនោះមានការចាប់អារម្មណ៍ចង់ចេះចង់ដឹង យកចិត្តទុកដាក់ ស្គាល់ពីតម្លៃនិងសារៈសំខាន់របស់ចំណេះដឹងទាំងនោះ ទើបធ្វើឲ្យគេ "**បើកទ្វារទទួលយក**" ទៅតាមវិធីផ្សេងៗដូចជា **ការអាន ការស្ដាប់ ការទស្សនា ឬការអនុវត្តតាមជាដើម។**

ការដែលបុគ្គលម្នាក់ៗ បើកទ្វារទទួលរៀនពីអ្វីផ្សេងៗបានល្អ ឬមិនល្អនោះ វាអាស្រ័យជាសំខាន់នៅលើរូបភាពក្នុងចិត្តរបស់បុគ្គលនោះ។ ប្រសិនបើបុគ្គលណាមានទំនោរនិយម **ស្គាល់ពីសារៈសំខាន់នៃចំណេះដឹង មានចិត្តចង់កសាងខ្លួនឱ្យបានល្អប្រសើរ មានចរិតនិស្ស័យឧស្សាហ៍ព្យាយាម ចេះដាក់ខ្លួនដាក់កាយរៀនសូត្រពីអ្នកដទៃ យល់ឃើញថា អ្នកណាក៏អាចយកធ្វើជាគ្រូរបស់ខ្លួនបានដែរ** [illegible] រកការស្រូបយកចំណេះផ្សេងៗបានល្អ។ ផ្ទុយទៅវិញ បើបុគ្គលនោះបែរជា

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

មានទំនោរនិយម មិនស្គាល់ពីតម្លៃនៃចំណេះដឹង គ្មានបំណងនឹងកសាងខ្លួនឲ្យកាន់តែប្រសើរ ចាប់អារម្មណ៍ទៅលើតែការសេពសោយ ស្រណុកសុខស្រួលតែម្យ៉ាង ជាប់និស្ស័យខ្ជិលច្រអូស អួតពូកែ អួតឆ្លាត គិតថាខ្លួនឯងអស្ចារ្យជាងអ្នកដទៃជាដើម បុគ្គលនោះ មានលក្ខណៈជាអ្នក “**បិទទ្វារ**” មិនព្រមទទួលយកការរៀនសូត្រពីអ្នកណាទាំងអស់។

**យើងសង្កេតឃើញថា ឥរិយាបថក្នុងចិត្ត វាអាចមានអំណោយផល ឬអាចជាឧបសគ្គដល់ការរៀនសូត្ររបស់មនុស្សយើង ដោយមិនអាចបដិសេធបានឡើយ។**

នៅក្នុងគ្រប់ថ្នាក់រៀនទាំងអស់ **សិស្សដែលមិនយកចិត្តទុកដាក់ស្តាប់ការពន្យល់របស់គ្រូ** ទោះជាក្នុងហេតុផលណាក៏ដោយ គេមុខជានឹងមិនយល់មេរៀន មិនអាចធ្វើកិច្ចការបាន បានពិន្ទុមិនសូវល្អ ឬប្រឡងធ្លាក់។ អ្វីទាំងនេះ ដោយសារតែការ “**បិទទ្វារ**” មិនទទួលយកការរៀននោះឯង។

ក្នុងករណីបែបនេះ យើងអាចចាត់ទុកថា គឺជាប្រការដែលមិនអាចបង្កើតឲ្យទៅជា “ដំណើរការរៀន” បានឡើយ ព្រោះវាខុសចាប់តាំងពីទឹកដំបូងមកចាត់ទៅហើយ (គឺគេគ្មានចិត្តចង់រៀន) ដូច្នេះដំណាក់កាលតៗមកទៀត ក៏វានៅតែមិនអាចទៅរួចបានដែរ។

*“ វាអាចមានដែរ នៅពេលយើងបញ្ចូលការពិតរាប់លានមុខទៅក្នុងខួរក្បាលមនុស្សម្នាក់ ហើយគេនៅតែជាមនុស្ស “អវិជ្ជា” ដដែល ”*

**អាឡិច ប៊ួន** – **Alec Bourne**

(ការដែលពុំមានចិត្តចង់រៀន វាមិនខុសអីពី “ចាក់ទឹកលើក្បាលទា” នោះឡើយ)

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

ដួយពីករណីខាងលើ ចំពោះអ្នកដែលមានការយកចិត្តទុកដាក់ មានចិត្តចង់ចេះចង់ដឹង តាំងស្មារតីស្ដាប់ការពន្យល់ ធ្វើការកត់ត្រា សាកសួរនូវអ្វីដែលខ្លួនមិនយល់ គេមានឱកាសនឹងបន្តដំណើរទៅវគ្គខាងមុខទៀតនៃដំណើរការរៀនរបស់គេ ព្រោះគេអាចឆ្លងផុតក្នុងដំណាក់កាលទីមួយបាន គឺដំណើរការ **"បើកចំហចិត្ត"** ឬ **"មានចិត្តចង់រៀន"** នោះឯង។

**"ចិត្ត"** មានសារៈសំខាន់ជាខ្លាំងក្នុងដំណើរការរៀនរបស់យើង។ **"ចិត្ត" គឺអ្នកកំណត់ថា តើយើងរៀនបានឬមិនបាន។ "ចិត្ត" ប្រៀបដូចជាមេទឹក បើមេទឹកពុំមានទឹកទេ ខ្សែទឹកទាំងឡាយក៏មិនអាចកើតមានបានដែរ។**

> *" ជោគជ័យនិងបរាជ័យរបស់បុគ្គល ដែលខុសគ្នាពីម្នាក់ទៅម្នាក់នោះ មួយផ្នែក មានឫសគល់មកពីសភាវៈចិត្តរបស់គេនោះឯង "*

### *ដំណាក់កាលទី២ : គិត វិភាគ ត្រិះរិះឱ្យទាល់តែយល់*

ការគិត វិភាគ ត្រិះរិះឲ្យយល់ គឺជាដំណាក់កាល តមកពីការបើកចំហចិត្តទទួលយកការចេះដឹង។

កាលបើយើង "មានចិត្តចង់រៀន" ហើយ យើងត្រូវប្រមូលយកមេរៀនឬព័ត៌មានទាំងនោះ មកគិត ត្រិះរិះពិចារណា ញែកញែករកហេតុផលរហូតដល់បានយល់ពិតប្រាកដ ទើបហៅថា បានឆ្លងផុតដំណាក់កាលទីពីរ។ តែប្រសិនបើយើងទទួលមេរៀន ឬព័ត៌មានអ្វីមួយចូលមក ដោយគ្រាន់តែបានកត់ត្រាទុកក្នុងប្រព័ន្ធចងចាំរបស់ខួរក្បាលតែម្យ៉ាង ឬចាប់ផ្ដើយតបភ្លាមៗ ដោយមិនបានគិតត្រិះរិះពិចារណា [illegible] មិនទាន់ចាត់ទុកថាជាការឆ្លងផុតដំណាក់កាលទីពីរនៅឡើយដែរ ព្រោះថា

www.facebook.
Fb : Entertainm

ការលោតរំលងដំណាក់កាលនៃដំណើរការរៀន វាប្រៀបប្រដូចទៅនឹងការដែលសិស្សគូសចម្លើយ ( Tick ✓ ) នៅលើវិញ្ញាសាគណិតវិទ្យាដូច្នោះដែរ។ គេអាចគូសចម្លើយបានត្រឹមត្រូវក៏ពិតមែន តែនេះពុំមែនជាការបញ្ជាក់ថា គេចេះពិតប្រាកដនៅឡើយដែរ ព្រោះគេមិនអាចស្រាយបញ្ជាក់បានទៅតាមដំណាក់កាលនីមួយៗនៃដំណោះស្រាយ ដើម្បីឲ្យបានចម្លើយពិតប្រាកដនោះទេ ហើយការដែលគេគូសចម្លើយបានត្រឹមត្រូវនោះ វាអាចគ្រាន់តែជារឿងចៃដន្យតែប៉ុណ្ណោះ និងបើពេលណាគេផ្លាស់ប្តូរសំណួរសាជាថ្មី គេក៏នឹងត្រូវប្រើវិធីហោងស៊ិយជាដដែលឡើងវិញ។

ហេតុនេះ បើគេចង់បញ្ចប់បញ្ហានេះ គេត្រូវតែវិលត្រឡប់ទៅកែសម្រួលដំណាក់កាលមុនៗឲ្យបានល្អសិន ដូចជា បង្កើតទស្សនៈល្អៗទៅលើមុខវិជ្ជាគណិតវិទ្យា បើកចំហចិត្តក្នុងការរៀន យកចិត្តទុកដាក់និងសាកសួរមិត្តភក្តិឬគ្រូបង្រៀន អំពីចំណុចដែលខ្លួនមិនទាន់យល់ ប្រើគំនិតត្រិះរិះរហូតដល់បានយល់យ៉ាងពិតប្រាកដ ទើបគេអាចដោះស្រាយវិញ្ញាសាបានត្រឹមត្រូវជារៀងរហូត(ពុំមានរឿងហោងស៊ិយ)។ ធ្វើបានដូច្នេះ ទើបយើងអាចចាត់ទុកថា ដំណើរការរៀនរបស់ខ្លួន បានរំកិលទៅមុខមួយកម្រិតទៀតហើយ។

ប្រទេសខ្មែរយើងអាចនឹងមានបញ្ហាក្នុងការ "ប្រើការគិត" បន្តិច ព្រោះថា ប្រព័ន្ធសិក្សាអប់រំរបស់យើង ចាប់តាំងពីសម័យមុនរហូតមកដល់សម័យបច្ចុប្បន្ននេះ យើងតែងប្រើវិធីបង្រៀនដោយផ្តោតសំដៅទៅលើការទន្ទេញចាំមាត់ ដូចជាវិជ្ជាប្រវត្តិសាស្ត្រជាដើម យើងចូលចិត្តឲ្យសិស្សចងចាំទៅលើហេតុការណ៍នោះកើតឡើងនៅឆ្នាំណា? មានទាក់ទងនឹងឈ្មោះណាខ្លះ? ទីកន្លែងណាខ្លះ? តែយើងបែរជាពុំសូវបើកឱកាស[illegible] ឲ្យសិស្សចេះវិភាគ ចេះវែកញែក ពិចារណាអំពីរឿងហេតុដែលកើតឡើងក្នុង

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

ប្រវត្តិសាស្ត្រអ្វីប៉ុន្មានទេ។ តាមពិតយើងគួរតែទម្លាប់ឲ្យគេរៀនធ្វើការវិភាគ ជុំកញ្ចែក ពិចារណាអំពីប្រវត្តិសាស្ត្រ ដើម្បីឲ្យយុវជនជំនាន់ក្រោយបាននាំមេរៀនពីអតីតកាល យកមកប្រើជាប្រយោជន៍ក្នុងបច្ចុប្បន្ន ឬដើម្បីការពារបញ្ហាផ្សេងៗនាពេលអនាគតផងដែរ។ បើយើងអាចធ្វើបានដូច្នេះ វាជាការជួយហ្វឹកហាត់ឲ្យយុវសិស្សរបស់យើង បានរៀនគិតពិចារណា មានភាពស្ទាត់ជំនាញក្នុងការប្រើហេតុផល និងដុះដាលខាងប្រាជ្ញាស្មារតីបានល្អ ដែលប្រសើរជាងការរៀនតាមតែ **"មេរៀនផ្សំស្រេច"** មិនចេះប្រើការគិតរបស់ខ្លួនឯង ពូកែតែខាងប្រើអារម្មណ៍ក្នុងការសម្រេចចិត្ត ដែលជាការបង្កបញ្ហាដដែលៗដល់ខ្លួនឯងនិងសង្គម ដ៏មិនចេះចប់មិនចេះហើយនោះឯង។

*" ទោះបីជាយើងត្រូវប្រើ "មេរៀនផ្សំស្រេច"*
*ដើម្បីឲ្យមនុស្សដើរតាម តែយើងគួរតែបំប៉នឲ្យបានច្រើន*
*អំពី "ការរៀនហ្វឹកហាត់ត្រិះរិះពិចារណា" ដល់យុវសិស្ស*
*ព្រោះការរៀនហ្វឹកហាត់ត្រិះរិះពិចារណា*
*វានឹងជួយឲ្យមនុស្ស បានទៅជា "មនុស្ស" ពេញលេញ "*

* * *

⇨⇨⇨

www.elibraryofcambodia.org www.facebook.
Fb : Entertainm

មនុស្សខ្លះ បានធ្វើអ្វីខុសម្តងរួចហើយ គេនឹងមិនធ្វើឱ្យខុសជាលើកទីពីរទៀតទេ គេអាចនឹងធ្វើខុសលើរឿងផ្សេងទៀត តែមិនមែនរឿងដដែលៗសាជាថ្មីទៀតឡើយ។ អ្វីទាំងនេះ គឺដោយសារគេបាននាំមេរៀនចាស់ៗ ឬកំហុសច្គងដែលធ្លាប់មានពីមុន យកមកវែកញែក ត្រិះរិះ ពិចារណា រហូតដល់មើលឃើញច្បាស់ថា កំហុសច្គងទាំងនោះ កើតឡើងដោយសារអ្វី? តើខ្លួនត្រូវកែលម្អ កសាងវាឡើងវិញដូចម្តេចខ្លះ?

ប្រធានគ្រប់គ្រងក្រុមហ៊ុនមួយកន្លែងបានសន្មតក្នុងចិត្តថា មនុស្សគឺជាអ្នកដែលមានចិត្តគំនិតទទួលខុសត្រូវខ្ពស់ មានការរីកចម្រើន។ ហេតុនេះគេមិនចាំបាច់ប្រើច្បាប់ទម្លាប់ឬក្រឹត្យក្រម យកមកគ្រប់គ្រងឱ្យជ្រុលហួសហេតុពេកឡើយ ដោយគ្រាន់តែផ្តល់កិត្តិយស លើកតម្លៃដល់អំពើល្អរបស់គេ និងផ្តល់ឥស្សរភាពដល់គេ គេប្រាកដជានឹងសម្តែងអាកប្បកិរិយាយ៉ាងសមរម្យត្រឡប់មកវិញជាមិនខាន។

គិតឃើញដូច្នេះហើយ លោកប្រធានក៏ប្រកាសឈប់ឱ្យមានការចុះហត្ថលេខាលើបញ្ជីម៉ោងចេញចូលធ្វើការ ដោយសង្ឃឹមថា បុគ្គលិកអ្នកធ្វើការទាំងអស់ គេនឹងគោរពវិន័យ រក្សាកិត្តិយសរបស់ខ្លួនឯង មិនកេងយកចំណេញពីលើក្រុមហ៊ុនដោយចូលក្រោយម៉ោង ឬចេញមុនម៉ោងអ្វីឡើយ។

លុះដល់ពិនិត្យជាក់ស្តែង ពួកគេមិនបានធ្វើដូចលោកប្រធានគាត់គិតឯណា ពេលដែលពុំមានច្បាប់ទម្លាប់សម្រាប់គ្រប់គ្រង បុគ្គលិកភាគច្រើនស្ទើរតែ 90% សុទ្ធតែចូលធ្វើការយឺត ហើយចេញមុនម៉ោងជារៀងរាល់ថ្ងៃ។ មានអ្នកខ្លះ ម៉ោង៩ឬ១០បានចូលធ្វើការ ឯអ្នកមួយចំនួនទៀតចេញពីធ្វើការមុនម៉ោងប្រហែលមួយម៉ោងឯណោះ។ ក្រោយពីនោះពេល១ខែ លោកប្រធានបានប្រកាសច្បាប់ ឱ្យបុគ្គលិកគ្រប់គ្នាត្រូវចុះហត្ថលេខាសាជាថ្មីឡើងវិញ។

www.facebook.
Fb : Entertainm

ចាប់ពីពេលនោះមក គាត់មិនដែលនឹកនាថា នឹងប្រកាសឈប់ប្រើច្បាប់លស់លាអ្វីទៀតឡើយ ដោយសារតែគាត់បាននាំយកហេតុការណ៍ដែលកើតឡើងនោះមកពិគ្រោះ ពិចារណា រហូតដល់ភ្លឺភ្នែក កើតជាបញ្ហានិងសរុបក្ដីសន្និដ្ឋានថា មនុស្ស មិនមែនជាអ្នកដែលមានចិត្តគំនិតរក្សានូវអំពើល្អយ៉ាងខ្ជាប់ខ្ជួនអ្វីឡើយ កាលបើមានឱកាស គេអាចនឹងប្រព្រឹត្តនូវអំពីដែលមិនសមរម្យ មានចរិតអាត្មានិយម យកប្រៀបលើអ្នកដទៃជានិច្ច។ ហេតុនេះ គេចាំបាច់ត្រូវមានច្បាប់ទម្លាប់បែបបទដ៏តឹងរ៉ឹង ដើម្បីគ្រប់គ្រង។

យុគបច្ចុប្បន្ន ជាសម័យដែលសម្បូរហូរហៀរទៅដោយទិន្នន័យព័ត៌មាន មកពីគ្រប់ទិសទីជុំវិញពិភពលោក ដែលចាក់ទាំងគំនរមកលើសង្គមយើងគ្រប់ពេលវេលា។ ទិន្នន័យព័ត៌មានទាំងនោះ មួយចំនួនមានប្រយោជន៍សម្រាប់មនុស្សទូទៅ មួយចំនួនទៀតមានប្រយោជន៍សម្រាប់មនុស្សក្នុងក្រុមណាមួយតែប៉ុណ្ណោះ ហើយក៏មានខ្លះទៀតដែរ ដែលបង្កប់ដោយពិសពុលដែលអ្នកទទួលខ្លះមិនទាំងបានដឹងខ្លួនផង។ ហេតុនេះ លោកអ្នកដែលទទួលយកទិន្នន័យព័ត៌មានទាំងនោះ មិនគួរបើកចំហចិត្ត ទទួលយកអ្វីៗគ្រប់យ៉ាងទាំងបិទភ្នែកនោះទេ តែយើងគួរតែចេះត្រិះរិះពិចារណា បែកចែកព័ត៌មានទាំងនោះឲ្យដឹងថា ព័ត៌មានបែបណាដែលមានប្រយោជន៍ យើងគួរទទួលយកមករៀនសូត្រ ព័ត៌មានបែបណាដែលពុំមានប្រយោជន៍ឬបង្កប់ទៅដោយពិសពុល យើងក៏មិនគួរទទួលវាឲ្យមកមានឥទ្ធិពលលើជីវិតរបស់ខ្លួនឡើយ។

**ជោគជ័យដ៏ពិតប្រាកដរបស់មនុស្សក្នុងសម័យបច្ចុប្បន្ន វាអាស្រ័យនៅលើសមត្ថភាពនៃការគិតត្រិះរិះ ពិចារណា ចេះជ្រើសរើសយកចំណេះដឹងណាដែលមានប្រយោជន៍មកអនុវត្ត [illegible] និងជួយជំរុញឱ្យមានសកម្មភាពជាវិជ្ជមានរបស់ខ្លួនបាន។ ផ្ទុយទៅវិញ យើង**

www.elibrary...
www.facebook.
Fb : Entertainm

កៅត្រូវចេះកម្ចាត់ចោលនូវព័ត៌មាន ឬគំនិតណាដែលមានលក្ខណៈមិនល្អ ឱ្យវាចេញផុតពីដំណើរការទទួលដឹងរបស់យើងផងដែរ។

### ៣- *ដំណាក់កាលទី៣ : ការរៀន ត្រូវតែនាំទៅដល់ការអនុវត្តន៍ប្រើប្រាស់ទៅរកភាពចម្រើនជឿនលឿនក្នុងផ្លូវល្អ ផ្លាស់ប្តូរទស្សនៈនិងការលើកតម្លៃ។*

ការរៀនអ្វីៗក៏ដោយ ពេលដែលចូលមកដល់ដំណាក់កាលទីពីរ គឺការគិត ត្រិះរិះពិចារណារហូតបានយល់ច្បាស់ហើយនោះ វានឹងនាំឱ្យកើតមានផលពីរយ៉ាង អាចជាផ្លូវណាមួយ ឬទាំងពីរផ្លូវតែម្តង ដើម្បី ៖

*១- អនុវត្តប្រើប្រាស់ ដើម្បីភាពចម្រើនជឿនលឿនក្នុងផ្លូវល្អ*
*២- ផ្លាស់ប្តូរទស្សនៈនិងការលើកតម្លៃ*

### ១- អនុវត្តប្រើប្រាស់ ដើម្បីភាពចម្រើនជឿនលឿន

ការរៀនដ៏ពិតប្រាកដ កើតមានឡើងនៅពេលដែលយើងសិក្សាស្វែងយល់ទៅលើទិន្នន័យឬព័ត៌មានបានច្បាស់លាស់ ហើយនាំអ្វីដែលខ្លួនបានរៀនចេះ យកមកអនុវត្តប្រើប្រាស់ឱ្យកើតជាប្រយោជន៍ក្នុងផ្លូវល្អចំពោះខ្លួនឯង ចំពោះបុគ្គលដែលខ្លួនស្រឡាញ់ ឬចំពោះសង្គម។ ឧទាហរណ៍ ៖

អ្នកដែលមានចំណេះដឹងខាងផ្នែកច្បាប់ គេនឹងមិនមានឈ្មោះថាជាអ្នកចេះពិតប្រាកដបានទេ ដរាបណាគេមិនបានយកចំណេះដឹងផ្នែកច្បាប់មកអនុវត្តប្រើឱ្យកើតជាប្រយោជន៍ក្នុងផ្លូវល្អទាំងបីកម្រិតគឺ ៖

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

1- **ប្រើជាប្រយោជន៍ចំពោះខ្លួនឯង :** ជាការប្រើប្រាស់ចំណេះដឹងដោយចាប់ផ្តើមពីរឿងតូចៗជាមុន គឺដើម្បីខ្លួនឯង ដូចជា ការការពារខ្លួនឱ្យផុតពីការសង្កត់សង្កិន ផុតពីការដើរខ្សែលើរបស់អ្នកដទៃ មិនឱ្យលង់ខ្លួនទៅប្រព្រឹត្តអំពើខុសច្បាប់ ប្រកបមុខរបរដោយសុចរិត ប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវសីលធម៌វិជ្ជាជីវៈជាដើម។

2- **ប្រើជាប្រយោជន៍ចំពោះបុគ្គលដែលខ្លួនស្រឡាញ់ :** ជាការឈានទៅរកការប្រើជាប្រយោជន៍សម្រាប់បុគ្គលដែលខ្លួនស្រឡាញ់ ដូចជាការថែរក្សាការពារផលប្រយោជន៍គ្រួសារ ការធ្វើជាទីប្រឹក្សាខាងច្បាប់ឱ្យដល់ញាតិមិត្តក្នុងរឿងរ៉ាវផ្សេងៗជាដើម។

3- **ប្រើជាប្រយោជន៍ចំពោះសង្គម :** ជាការឈានទៅរកការប្រើជាប្រយោជន៍ដែលទូលំទូលាយជាងមុន អាចជារូបភាពនៃការបម្រើសេវាផ្លូវច្បាប់ឱ្យដល់អ្នកដែលទន់ខ្សោយ អ្នកដែលរងនូវភាពអយុត្តិធម៌ក្នុងសង្គម ឬឈរឈ្មោះបោះឆ្នោតជាសមាជិកសភា ដើម្បីជួយរៀបចំតាក់តែងច្បាប់រដ្ឋត្រិះរិះលើកសំណើយកច្បាប់ណាដែលមានប្រយោជន៍ដល់ប្រជាជនជាដើម។

ផ្ទុយពីនេះវិញ បុគ្គលដែលគ្រាន់តែមានចំណេះ ឬយល់ដឹងជ្រៅជ្រះចេះច្បាប់ពេញខ្លួនយ៉ាងណាក៏ដោយ តែបើមិនបានយកចំណេះទៅប្រើឱ្យកើតជាប្រយោជន៍ក្នុងផ្លូវល្អទេ តែត្រឡប់ទៅជាធ្វើកិច្ចសន្យាខុស នាំឱ្យខូចខាតទ្រព្យសម្បត្តិដោយមិនចាំបាច់ ឬមិនអាចការពារផលប្រយោជន៍របស់ក្រុមញាតិមិត្តបានទេ ឬបែរជាយកចំណេះខាងផ្លូវច្បាប់ទៅបម្រើផលប្រយោជន៍របស់ខ្លួននិងបក្សពួកដោយឧបាយកលទុច្ចរិត បុគ្គលនោះនឹងមិនមានឈ្មោះថាជាអ្នកដែលបានថ្លឹងកាត់ "ដំណើរការរៀន" ពេញលេញនោះឡើយ។

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

អ្នកច្បាប់មួយចំនួនសុខចិត្តទទួលបម្រើអ្នកមានអំណាច ដើម្បីស្វែងរកផលប្រយោជន៍សម្រាប់ខ្លួនឯង រហូតដល់សុខចិត្តលើកចោលនូវគុណធម៌និងចរិយាធម៌ទាំងមុខក្រាស់ឃ្នើក ព្រមធ្វើគ្រប់យ៉ាងដើម្បីការពារចៅហ្វាយ ឬការពារកូនក្តី ហ៊ានប្រើល្បិចកលថោកទាបជាន់ឈ្លីជនស្លូតត្រង់។ បុគ្គលប្រភេទនេះ គ្រាន់តែជាអ្នកចេះដឹងក្លែងក្លាយប៉ុណ្ណោះ និងជាការគួរឱ្យស្តាយអំពីសមត្ថភាពដែលគេមាន។ ប្រសិនបើគេយកចំណេះមកប្រើជាប្រយោជន៍ដល់សង្គមនិងប្រទេសជាតិបានពេញលេញនោះ វានឹងនាំឱ្យកើតជាផលល្អហើយមានតម្លៃយ៉ាងខ្ពង់ខ្ពស់បំផុត មិនអាចកាត់ថ្លៃបានឡើយ។

## ២- ផ្លាស់ប្តូរទស្សនៈនិងការលើកតម្លៃ

មានពេលខ្លះ “ការរៀនស្វែងយល់” មិនបានហុចលទ្ធផលឱ្យយើងបានឃើញនៅនឹងភ្នែក ឬយកទៅប្រើប្រាស់អ្វីឡើយ ប៉ុន្តែវាជាលទ្ធផលដែលកើតមានឡើងនៅក្នុងចិត្ត គឺការផ្លាស់ប្តូរទស្សនៈឬការលើកតម្លៃចេញពីជ្រុងមួយទៅជ្រុងមួយទៀត ចេញពីការយល់ឃើញម្យ៉ាង ឱ្យទៅជាការយល់ឃើញមួយបែបផ្សេងទៀត។

មនុស្សម្នាក់ មានគំនិតមិនល្អទៅលើអ្នកមានមេរោគអេដស៍។ គេតែងមានអារម្មណ៍ខ្ពើមរអើម មិនចង់សេពគប់ជាមួយ ព្រោះខ្លាចក្រែងឆ្លងមេរោគពីពួកគេទាំងនោះ។ ក្រោយពីបានទស្សនាខ្សែភាពយន្តផ្នែកអប់រំមួយដែលបង្ហាញឱ្យឃើញថា អ្នកដែលមានផ្ទុកមេរោគអេដស៍ មិនមែនជាបុគ្គលដែលគួរឱ្យស្អប់ខ្ពើមអ្វីទេ គេនៅតែជាពលរដ្ឋដ៏មានតម្លៃរបស់ប្រទេសជាតិ គេនៅអាចធ្វើការបម្រើសង្គមដូចជាមនុស្សដទៃអញ្ចឹងដែរ ហើយអ្នកខ្លះក៏ជាមនុស្សដែលមានទិស្សយ័យល្អ។ [illegible] ទៀតផង ចំណែកមេរោគប្រភេទនេះ ក៏មិនមែនចេះតែឆ្លងដោយងាយៗដែរ។

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

នៅពេលដែលគេកំពុងទស្សនាភាពយន្តនោះជាបណ្តើរៗ ដំណើរការគិតរបស់គេក្នុងពេលនោះក៏ធ្វើការព្រមៗគ្នាដែរ ។ គេគិត ត្រិះរិះ វិភាគ ពិចារណាចុះឡើង ហើយក៏នឹកឃើញក្នុងចិត្តថា រយៈពេលកន្លងមក គេធ្លាប់មានទស្សនៈមិនល្អចំពោះមនុស្សទាំងនោះ និងមានការព្រួយបារម្ភខុសរឿង។

ដោយសារការស្វែងយល់ទាំងនេះ ធ្វើឱ្យគេមានការផ្លាស់ប្តូរអំពីទស្សនៈក្នុងចិត្តរបស់ខ្លួនពីមួយបែបទៅមួយបែបទៀត គឺឈប់ស្អប់ខ្ពើមពួកគេ ហើយបែរទៅជាមានចិត្តអាណិតអាសូរទៅវិញ ព្រមទាំងមិនមានការព្រួយបារម្ភក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកទាំងនោះទៀតផង។

បុគ្គលដ៏មានមហិច្ឆិតាម្នាក់ ខំរកស៊ីរហូតក្លាយជាអ្នកមានទ្រព្យសម្បត្តិរហូតដល់រាប់លានដុល្លារ។ គេមានទស្សនៈថា " ឲ្យតែមានលុយ គឺមានអ្វីៗទាំងអស់ "។ លុយនេះហើយ គឺជាសេចក្តីសុខក្នុងជីវិតរបស់ខ្លួន។ ទស្សនៈនេះ ធ្វើឱ្យគេខ្វល់ខ្វាយអំពីរឿងលុយមិនចេះឈប់ឈរ ទោះបីជាខ្លួនមានទ្រព្យសម្បត្តិរហូតដល់ "ស៊ីមួយជីវិត" មិនអស់ក៏ដោយ គេនៅតែមើលឃើញអ្នកដទៃមានជាងខ្លួន ជាហេតុធ្វើឱ្យជីវិតបច្ចុប្បន្នរបស់គេនៅតែពុំអាចរកឃើញសេចក្តីសុខជាដដែល។

ថ្ងៃមួយដោយស្ថានការណ៍ពិភពលោកប្រែប្រួល(ដីចុះថ្លៃ?) គេត្រូវខាតបង់ទ្រព្យសម្បត្តិអស់ជាងពាក់កណ្តាល គេកើតទុក្ខជាខ្លាំងរហូតដល់ធ្លាក់ខ្លួនឈឺជាទម្ងន់។ មានមិត្តភក្តិម្នាក់ បានមកសួរសុខទុក្ខ ព្រមទាំងផ្តល់យោបល់ដល់គេថា

"សម្លាញ់! ទោះបីជាសម្លាញ់ឯងខាតបង់ទ្រព្យសម្បត្តិអស់ច្រើនយ៉ាងនេះហើយក៏ដោយ តែទ្រព្យសម្បត្តិរបស់សម្លាញ់ដែលនៅសេសសល់ទាំងនោះ សម្លាញ់ឯងចាយមួយជីវិតក៏មិនអស់ផង ហេតុនេះ សម្លាញ់ឯងនៅឱបទុក្ខសោករហូតដល់ធ្លាក់ខ្លួនឈឺបែបនេះ តើវាបានប្រយោជន៍អ្វីទៅ?

www.elibraryofcambodia.org www.facebook. Fb : Entertainm

តើសម្លាញ់មានដែលគិតទេថា កាលពីនៅក្រីក្រ សម្លាញ់ឯងហាក់ដូចជាមានសេចក្ដីសុខជាងនេះទៅទៀត ហេតុអីក៏នៅពេលនេះ សម្លាញ់បែរជាមានទុក្ខជាងកាលពីខ្លួននៅក្រទៅវិញ? "

និយាយចប់ហើយ មិត្តភក្ដិនោះក៏ប្រគល់សៀវភៅពីរបីក្បាលឲ្យសំឡាញ់របស់គាត់យកទៅអាន។ ក្រោយពីនោះប្រមាណមួយខែ ធ្លងកាត់ដំណាក់កាលរៀនគិតត្រិះរិះមក បុគ្គលនោះ ត្រឡប់ទៅជាមានទស្សនៈមួយផ្ទុយពីមុនដែលថា លុយកាក់ មិនមែនជាអ្វីគ្រប់យ៉ាងរបស់មនុស្សនោះទេ ជាពិសេស "សេចក្ដីសុខ" បើចិត្តយើងនៅតែលោភលន់ ទោះបីជាមានលុយកាក់ច្រើនប៉ុនណាក៏នៅតែមិនបានសុខ។ ផ្ទុយទៅវិញ បើចិត្តរបស់យើងវាចេះគ្រប់ចេះល្មម រស់នៅក្នុងខ្ទម បាយជាមួយស្ងោរស្ពុំត្រីកញ្ចុះ ក៏យើងនៅតែរកសេចក្ដីសុខបានដែរ។

ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្ដូរទស្សនៈ ការផ្លាស់ប្ដូរការលើកតម្លៃដ៏ពិតប្រាកដនោះ វាត្រូវតែស្ដែងចេញឲ្យឃើញតាមរយៈទង្វើ ឬជាសកម្មភាពអ្វីមួយមកខាងក្រៅដែរទើបយើងអាចចាត់ទុកថា បុគ្គលនោះពិតជាបានផ្លាស់ប្ដូរ ពិតជាអ្នកដែលបានធ្លងកាត់ "ដំណើរការរៀន" យ៉ាងពេញលេញប្រាកដមែន។

*" ការផ្លាស់ប្ដូរទស្សនៈ ឬចំណង់ចំណូលចិត្តដ៏ពិតប្រាកដ*
*វាត្រូវតែស្ដែងចេញមកតាមរយៈសកម្មភាព ឬរូបភាពអ្វីម្យ៉ាងៗ "*

www.elibraryofcambodia.org
www.facebook.
⇨⇨⇨
Fb : Entertainm

**ក្នុងករណីទី១** បុគ្គលនោះត្រូវបង្ហាញឱ្យឃើញពីសកម្មភាពផ្សេងៗ ដូចជា ការនិយាយរាក់ទាក់ជាមួយអ្នកមានមេរោគអេដស៍យ៉ាងស្និទ្ធស្នាល អាចរួមបរិភោគអាហារជាមួយពួកគេ ធ្វើជាមិត្តរបស់ពួកគេ ជួយផ្តល់ការលើកកម្លាំងចិត្តដល់ពួកគេនៅពេលពួកគេបាក់ទឹកចិត្តជាដើម។

**ក្នុងករណីទី២** បុគ្គលដែលធ្លាប់តែឃើញលុយជាធំ ត្រូវបង្ហាញឱ្យឃើញថា ខ្លួនមិនជាប់ជំពាក់នឹងលុយហួសហេតុទៀតទេ វាមានអ្វីផ្សេងៗជាច្រើនទៀតដែលមានសារៈសំខាន់ក្នុងជីវិត ដូចជា ចេះរស់ឱ្យមានក្តីសុខក្នុងស្ថានភាពបែបណាក៏ដោយ ចេះសម្លឹងមើលមកអ្នកដែលខ្សត់ខ្សោយជាងខ្លួនឯង ចេះចែករំលែកដល់មនុស្សជុំវិញ និងជាពិសេស គេយល់ដឹងបានយ៉ាងច្បាស់ថា ទោះជាខ្លួនមានទ្រព្យសម្បត្តិហូរហៀរយ៉ាងណាក៏ដោយ គេអាចគ្រប់គ្រងបានតែមួយរយៈប៉ុណ្ណោះ ពេលស្លាប់ទៅ មិនមាននណាអាចយកវាទៅជាមួយបានឡើយ។

ការគ្រាន់តែបានផ្លាស់ប្តូរទស្សនៈ ឬប្តូរការលើកតម្លៃនៅតែក្នុងចិត្តរបស់ខ្លួន តែបើពុំមានជាសកម្មភាព ឬជាទង្វើអ្វីឱ្យកើតមានជាផលល្អៗសមស្របទៅតាមទស្សនៈថ្មី ឬការលើកតម្លៃបែបថ្មីទាំងនោះទេ យើងក៏មិនអាចនិយាយថា បុគ្គលនោះជាអ្នកដែលបានរៀន ឬជាអ្នកដែលបានឆ្លងកាត់ "ដំណើរការរៀន" ដ៏ពេញលេញពិតប្រាកដដែរ ។

*" គ្រូថា មិនឈ្នះគ្រូធ្វើ "*

**ការគ្រាន់តែគិត ឬគ្រាន់តែនិយាយតែមាត់**

**វាមិនអាចបញ្ជាក់ពីការពិតអ្វីឡើយ**

**ដរាបណា យើងពុំមានបេះដូងក្នុងការអនុវត្តន៍ដោយពិតប្រាកដទេនោះ។**

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

**ឧទាហរណ៍** ក្នុងនាមយើងជាខ្មែរ ដែលមានពូជអម្បូរបុព្វបុរសជាអ្នកកសាងប្រាសាទបុរាណដ៏ល្បីល្បាញពេញទាំងសកលលោក និងក្នុងនាមយើងទាំងអស់គ្នាដែលជាកូនចៅតពូជពង្សពីបុព្វបុរសទាំងនោះ យើងតែងលើកសរសើរនិងមានមោទនភាពជាខ្លាំងចំពោះបុព្វបុរសរបស់យើង។ យើងតែងនាំគ្នារាំច្រៀង ដើម្បីរំឭកអំពីភាពអស្ចារ្យដែលដូនតាយើងធ្លាប់ធ្វើកាលពីសម័យមុន។ ប៉ុន្តែយើងគ្រប់គ្នាក៏ត្រូវភ្ញាក់រឭកផងដែរថា ការនិយាយកោកៗតែមាត់ តែបើពុំមានបេះដូងក្នុងការធ្វើអ្វីៗដើម្បីតបស្នងដល់បុព្វបុរសទេ ពាក្យសម្ដីទាំងប៉ុន្មានរបស់យើង ក៏ពុំមានតម្លៃអ្វីដែរ។ ហេតុនេះដើម្បីឆ្លើយតបទីងអ្វីដែលយើងបាននិយាយ យ៉ាងហោចណាស់ក៏សុំឱ្យកើតមានជាទង្វើខ្លះៗដូចជា អំពើល្អដោយបរិសុទ្ធ ឬស្មារតីសាមគ្គីចំពោះជនរួមជាតិ ឬស្មារតីថែរក្សាទ្រព្យសម្បត្តិជាតិជាដើម។ ទាំងនេះ គឺជាអ្វីដែលបងប្អូនជាប្រជារាស្ត្រសាមញ្ញអាចធ្វើបានគ្រប់ៗគ្នា និងក្រៅពីនេះ ប្រសិនបើយើងមានសមត្ថភាពអាចសម្រេចរឿងធំៗជូនជាតិបាន នោះវាកាន់តែជួយឱ្យយើងជាប់ស្នាមកវិញនូវអ្វីដែលយើងធ្លាប់ដុនដាបពីមុននោះផងដែរ។

☞ *ដើម្បីសម្រេចការរៀនឲ្យបានពេញលេញ*
*យើងត្រូវអនុវត្តឲ្យបានតាមដំណាក់កាលទាំងបីគឺ*
*១- បើកចំហចិត្ត ហានចិត្តចង់រៀន ស្គាល់តម្លៃនៃការរៀន*
*២- យកអ្វីដែលរៀនមកគិតត្រិះរិះឲ្យបានយល់ច្បាស់*
*៣- យកចំណេះទៅបំពេញឲ្យកើតជាប្រយោជន៍ក្នុងផ្លូវល្អ*
*និងនាំទៅដល់ការផ្លាស់ប្ដូរទស្សនៈនិងការលើកតម្លៃនៃអ្វីល្អៗ*
*តែយើងក៏មិនត្រូវបំភ្លេចដែរថា យើងត្រូវមានគោលបំណងជាមុន*
*ព្រោះបើគ្មានគោលដៅអីទេ វាក៏គ្មានថាមពលឲ្យចង់រៀនដែរ។*

www.library.com.kh
www.facebook.
Fb : Entertainm

អ្នកត្រូវស្វែងយល់ពីអ្វីគ្រប់យ៉ាងនៃជីវិត មិនមែនមើលតែមួយជ្រុងនោះទេ
នោះគឺជាហេតុផលដែលថា
ហេតុអ្វីទើបអ្នកត្រូវអាន? ហេតុអ្វីបានជាអ្នកត្រូវសម្លឹងទៅលើមេឃ?
ហេតុអ្វីបានជាអ្នកត្រូវច្រៀងរាំ? សរសេរកំណាព្យ?
ហេតុអ្វីក៏ត្រូវរងទុក្ខវេទនា? ហេតុអ្វីក៏ត្រូវយល់ដឹង?
ព្រោះអ្វីៗទាំងនោះ គឺជីវិត។

**ក្រឹស្ណាមូរធិ (1895 -1986)**

ទស្សនវិទូឥណ្ឌា

ជីវិតប្រៀបដូចជាសម្លកកូរដូច្នោះ វាមានទាំងបន្លែផ្អែម បន្លែល្វីង
ប្រកបដោយរសជាតិចម្រុះគ្នា។
យ៉ាងណាមិញ សុខនិងទុក្ខ គឺជារឿងដែលមនុស្សម្នាក់ៗត្រូវតែជួប
ដោយមិនអាចគេចវេះបានឡើយ។
(អ្នកបកប្រែ)

www.elibraryofcambodia.org
www.facebook.
Fb : Entertainm

ការសិក្សា គឺការរកឃើញបន្តិចម្តងៗ
អំពីអ្វីដែលខ្លួនមិនដឹង។

Education is a progrssive discovery
of our own ignorance.

**វិល ឌុយរ៉ង់ - Will Durant**

☆ ☆ ☆



www.elibraryofcambodia.org www.facebook.
Fb : Entertainm

# ៣

# សារប្រយោជន៍នៃ "ការរៀន"

***" ជីវិតគឺការរៀន ការរៀនគឺជីវិត "***

ពំនោលនេះ បង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីសារៈសំខាន់នៃការរៀន។ ជីវិតដែលនឹងមានដំណើរប្រកបដោយសេចក្ដីសុខ និងសម្រេចបានជោគជ័យត្រូវអាស្រ័យដោយ "ការរៀន"។ ការរៀន គឺជាផ្នែកមួយនៃជីវិតដែលមិនអាចគេចវេះជៀសវាង។ បើពុំមានការរៀនទេ ជីវិតនឹងត្រូវគាំងស្ទៀមដូចគេចុចជីពចរ មិនអាចដើរឆ្ពោះទៅរកក្ដីរុងរឿងបានឡើយ។

សេចក្ដីសុខនិងជោគជ័យរបស់មនុស្ស ត្រូវចាប់ចេញដំណើរឡើងពីការមើលឃើញតម្លៃនៃការរៀនសូត្រនោះឯង។ ការរៀនមានសារៈសំខាន់ចំពោះបុគ្គលម្នាក់ៗផង ហើយក៏មានសារៈសំខាន់ដល់លោកយើងព្រមទាំងមនុស្សជាតិលើលោកផងដែរ។ បើមនុស្សភាគច្រើននៅលើលោកសុទ្ធតែជាអ្នកដែលមិនបានរៀន ការអភិវឌ្ឍ [illegible] ដោយពិបាកបំផុត ឬស្ទើរតែមិនអាចដើរទៅមុខបាន (ដើរថយក្រោយ?)

www.facebook.
Fb : Entertainm

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ សៀង ស៊ីវ៉ាន់

មករា ឆ្នាំ ២០១៦

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

www.facebook.com/7khmer

Fb : Entertainment And Knowle